# សេចក្តីប្រកាសស្តីពី សិទ្ធិ
# អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង



Stop TB Partnership

TB PEOPLE

# សេចក្ដីប្រកាសស្ដីពី សិទ្ធិ
# អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង

បុព្វកថា

## យើងជាសហគមន៍ពិភពលោក នៃអ្នកធ្លាប់រស់នៅ និងរងផលប៉ះពាល់ដោយសារជំងឺរបេង

**ទទួលស្គាល់** ថាការលើកកម្ពស់ និងការពារសិទ្ធិ នៃអ្នកធ្លាប់រស់នៅ និងរងផលប៉ះពាល់ដោយសារជំងឺរបេងគឺមានលក្ខណៈស្របតាមក្រមសីលធម៌ និងស្របតាមច្បាប់ ហើយក៏មានសារៈសំខាន់បំផុត សម្រាប់ប្រសិទ្ធិភាពក្នុងឆ្លើយតបទៅនឹងការរាតត្បាត និងជាការបន្ធូរបន្ថយ នូវការឈឺចាប់នានាដែលកើតឡើងទៅលើបុគ្គល និងសហគមន៍ដែលរងគ្រោះ និងរងផលប៉ះពាល់ដោយសារជំងឺរបេង។

**ទទួលស្គាល់** ថាអ្នកដែលធ្លាប់រស់នៅ និងរងផលប៉ះពាល់ដោយជំងឺរបេង បាននិងបន្តទទួលរងនូវការរំលោភបំពានលើសិទ្ធិ ដោយគិតទាំងការឆ្លើយតបទៅនឹងជំងឺរបេង និងដោយសារការរំលោភបំពានទាំងនេះហើយ ដែលបង្កការរំខានដល់ការលុបបំបាត់ជំងឺរបេង ហើយបានបន្ថែមនូវភាពឈឺចាប់ដែលបង្កដោយជំងឺរបេងនេះ និងធ្វើឱ្យជំនឿទុកចិត្តរបស់អ្នក ដែលរងគ្រោះ និងរងផលប៉ះពាល់ដោយជំងឺរបេងមានការចុះថយ នៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ពួកគេ។

**សូមធ្វើការបញ្ជាក់** ថាអ្នកដែលរងគ្រោះនិងរងផលប៉ះពាល់ដោយជំងឺរបេង ផ្អែកលើបទពិសោធន៍ និងចំណេះដឹងផ្ទាល់របស់ពួកគេដែលធ្លាប់ឆ្លងកាត់កន្លងមក ទៅតាមគុណធម៌គប្បីត្រូវបានចូលរួមគ្រប់ដំណាក់កាលនៃការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃក្នុងកម្មវិធីរបេងនៅកម្រិតពិភពលោក កម្រិតតំបន់ កម្រិតជាតិ និងកម្រិតសហគមន៍។

**សូមគិតថា** វិធីសាស្ត្រវេជ្ជសាស្ត្រ ឬវិធីសាស្ត្រសុខភាពសាធារណៈតែមួយមុខមិនគ្រប់គ្រាន់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺរបេងនោះទេ ហើយវិធីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ផ្ដោត ឬគិតលើសិទ្ធិរបស់អ្នកជំងឺ សម្រាប់កម្មវិធីអប់រំបង្ការជំងឺរបេង ការផ្ដល់ការធ្វើតេស្ត ការព្យាបាល ការថែទាំ និងការគាំទ្រ ដែលជាផ្នែកមួយនៃការទទួលបានសេវាសុខាភិបាលជាសាកលគឺមានសារសំខាន់បំផុតក្នុងការបញ្ចប់ជំងឺរបេង និង

**សូមអះអាង** ថា ច្បាប់សិទ្ធិមនុស្សកម្រិតអន្តរជាតិ និងកម្រិតតំបន់ មានអាណត្តិ និងមានកាតព្វកិច្ច ផ្ដល់ខ្លឹមសារនៃសេចក្ដីប្រកាសនេះ ដែលត្រូវយកទៅប្រើ ស្របតាមតម្រូវការនៃច្បាប់ និងផ្ដល់ការស្រាយបញ្ជាក់ អំពីកាត

ពូកិច្ចផ្លូវច្បាប់របស់រដ្ឋ ឬប្រទេស ក្នុងបរិបទនៃការរាតត្បាត ជំងឺរបេង ដែលក្នុងនោះរួមមាន៖

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងទង្វើអមនុស្សធម៌ ឬមើលងាយផ្សេងៗ
- អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករចំណាកស្រុកទាំងអស់ និងសមាជិកនៃគ្រួសា ររបស់ពួកគេ
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- អនុសញ្ញាទាក់ទងនឹងឋានៈជនភៀសខ្លួន

និងនៅកម្រិតតំបន់ រួមមាន៖

- ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងប្រជាជន
- ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិ និងសុខុមាលភាពកុមារ
- អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស
- ធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស
- អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និង
- ធម្មនុញ្ញសង្គមរបស់អឺរ៉ុប

**និង ដោយការគិតពិចារណា** លើចំណុចផ្សេងៗទៀតដូចជា គោលដៅអភិវឌ្ឍប្រកបដោយចីរភាព នៃរបៀបវារៈឆ្នាំ ២០៣០ (SDGs 2030) សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សេចក្តីប្រកាសនយោបាយនៃកិច្ចប្រជុំជាន់ខ្ពស់របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងជំងឺរបេង ផែនការសកលសម្រាប់បញ្ចប់របេងរបស់ Stop TB Partnership សេចក្តីសំរេចចិត្តនៃកិច្ចប្រជុំរបស់អង្គការសុខភាពពិភពលោក គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច របាយការណ៍និងសេចក្តីប្រកាសរបស់អ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិស្តីពីសិទ្ធិសុខភាព និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិផ្សេងទៀត យុទ្ធសាស្ត្របញ្ចប់ជំងឺរបេងរបស់អង្គការសុខភាពពិភពលោក ដែលបានទទួលស្គាល់ និងអនុម័តិដោយរដ្ឋជាសមាជិកអង្គការសុខភាពពិភពលោក គឺបង្កើតបាននូវការការពារ និ

ងលើកតម្កើងសិទ្ធិមនុស្ស ក្រមសីលធម៌ និងសមភាព ក៏ដូចជាលើកកម្ពស់នូវសម្ព័ន្ធភាពរឹងមាំជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍ដែលជាគោលការណ៍គ្រឹះចាំបាច់ក្នុងការឆ្លើយតបនឹងជំងឺរបេង។

## បានបង្កើត និងសូមធ្វើការបង្ហាញ សេចក្តីប្រកាសស្តីពីសិទ្ធិរបស់អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង

## ជំពូកទី១. បទប្បញ្ញត្តិទូទៅ

### មាត្រា ១. **និយមន័យ**

សេចក្តីប្រកាសនេះប្រើប្រាស់និយមន័យដូចតទៅៈ

ការថែទាំសុខភាពសម្រាប់ជំងឺរបេងសំដៅទៅលើការព្យាបាលដែលរួមបញ្ចូលគ្នាជាមួយនឹងឧបករណ៍ និងសេវាថែទាំសុខភាពដែលមានគុណភាព និងមានប្រសិទ្ធភាពខ្ពស់បំផុតដែលមានទំនាក់ទំនងទៅនឹងការបង្ការការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលការឆ្លងរោគ និងការព្យាបាលជំងឺរបេង ដោយរាប់បញ្ចូល របេងក្នុងសួត របេងក្រៅសួត របេងដែលស៊ាំ និងរបេងមិនស៊ាំថ្នាំ ដែលមានផលរំខានតិចតួចបំផុត ដោយគិតនិងរាប់បញ្ចូល ការធ្វើរោគវិនិច្ឆ័យ ការផ្តល់ឱសថ ការផ្តល់ប្រឹក្សា ការផ្តល់សេវាគាំទ្រផ្នែកចិត្តសាស្ត្រសង្គម ការសម្រាកព្យាបាលនៅមន្ទីរពេទ្យរយៈពេលយូរ និងការផ្តល់សេវាថែទាំបន្តដល់អ្នកពិការភាពដោយផ្នែក និងជាអចិន្ត្រៃយ៍ តាមការចាំបាច់ ការថែទាំនៅតាមសហគមន៍ ការថែទាំបន្ទាប់បន្សំ និងការថែទាំនៅដំណាក់កាលនៃជីវិតចុងក្រោយ ការតាមដាន និងការគ្រប់គ្រងព្រឹត្តិការណ៍ដែលអាចកើតមានមកវិញក្នុងអំឡុងពេលព្យាបាល និងការផ្តល់អន្តរាគមន៍ និងដាក់ឧបករណ៍ព្យាបាល ដោយរាប់បញ្ចូលការថែទាំសង្គ្រោះបន្ទាន់ ដែលធ្វើដោយអ្នកផ្តល់សេវាថែទាំដែលទទួលបានការបណ្តុះបណ្តាល និងធ្វើក្នុងលក្ខណៈមិនមានការរើសអើង យល់ដឹងអំពីវប្បធម៌ប្រពៃណី គោរពភាពថ្លៃថ្នូរ និងផ្តល់ការគោរពចំពោះអ្នកជំងឺ មិនមានការបង្ខិតបង្ខំ ឬមាក់ងាយ ចាប់ពីគេបានឆ្លងរោគ និងឆ្លងជំងឺ និងអស់មួយជីវិតសម្រាប់អ្នកដែលត្រូវការនូវការថែទាំបន្ត។

អ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេង គឺសំដៅទៅលើអ្នកដែលមានជំងឺរបេងឬធ្លាប់កើតជំងឺរបេង ដោយរាប់បញ្ចូលអ្នកដែលផ្តល់ការថែទាំដល់ពួកគេសមាជិកគ្រួសារគេនិងសមាជិកនៃក្រុមប្រជាជនគន្លឹះនិងងាយរងគ្រោះដោយសារជំងឺរបេង រួមមានដូចជាកុមារ អ្នកផ្តល់សេវាថែទាំសុខភាព ជនជាតិភាគតិច អ្នករស់នៅជាមួយមេរោគអេដស៍ អ្នកប្រើប្រាស់ថ្នាំញៀន អ្នកជាប់ពន្ធនាគារ កម្មកររ៉ែត្បូង ក្រុមប្រជាជនផ្លាស់ប្តូរទីលំនៅ និងចល័ត ក្រុមស្ត្រី និងក្រុមជនក្រីក្រដែលរស់នៅតាមទីក្រុង និងជនបទ។

ជំងឺរបេង សំដៅទៅលើជំងឺរបេងគ្រប់សណ្ឋាន ដោយគិតទាំងរបេងសួត របេងក្រៅសួត របេងស៊ាំ និងមិនស៊ាំថ្នាំ។

## ជំពូកទី ២ សិទ្ធិអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង

### មាត្រា ២. **សិទ្ធិរស់រានមានជីវិត**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិពីកំណើតគឺសិទ្ធិរស់រានមានជីវិត។ ក្នុងនេះរួមបញ្ចូលទាំងសិទ្ធិទទួលបានការថែទាំសុខភាព និងព្យាបាលជំងឺរបេងដើម្បីបន្តជីវិតរស់នៅ។

### មាត្រា ៣. **សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិ ក្នុងការទទួលបានការយកចិត្តទុកដាក់ដោយសេចក្តីថ្លៃថ្នូរ និងដោយការគោរព។

នេះរួមបញ្ចូលទាំងការចាត់ទុកជាស្វ័យបុគ្គល (បុគ្គលស្វ័យភាព) និងភ្នាក់ងារនៃគុណតម្លៃរបស់បុគ្គល មិនមែនមានន័យថាត្រឹមតែសម្រាប់សុខភាពសាធារណៈទេ និងមិនត្រូវទទួលបាននូវការរើសអើង ការមាក់ងាយ ឬការបង្ខិតបង្ខំនានា ដោយរាប់បញ្ចូលទាំងនៅកន្លែងផ្តល់សេវាថែទាំសុខភាព និងនៅកន្លែងឃុំឃាំងផងដែរ។

### មាត្រា ៤. **សិទ្ធិទទួលបានសេវាសុខភាពផ្លូវកាយ និងផ្លូវចិត្តនៅកម្រិតស្តង់ដាខ្ពស់បំផុត (សិទ្ធិសុខភាព)**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបាននូវសេវាសុខភាពផ្លូវកាយ និងផ្លូវចិត្តនៅកម្រិតខ្ពស់បំផុត។

នេះរួមបញ្ចូលទាំងសិទ្ធិទទួលបាន រកបាន ទទួលយកបាន នូវការថែទាំសុខភាពដែលមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងជំងឺរបេង ដែលជាសមាសធាតុសំខាន់នៃការទទួលបានសេវាសុខភាពជាសាកលដោយរួមបញ្ចូល ការដាក់ចូលគ្នានូវកម្រិតថ្នាំជាក់លាក់ដែលមានលក្ខណៈកុមារមេត្រី និងការផ្តល់ការធ្វើតេស្ត ការផ្តល់ការព្យាបាលបង្ការសម្រាប់ប្រជាជនគន្លឹះ និងងាយរងគ្រោះដោយការឆ្លងជំងឺរបេង ពីពេលដែលគេបានបង្ហាញនូវសញ្ញាសង្ស័យថាមានជំងឺរបេង រហូតដល់បញ្ចប់ការព្យាបាល និងលើសពីនេះទៀតសម្រាប់អ្នកដែលត្រូវការនូវការថែទាំបន្តដែលនឹងត្រូវផ្តល់អោយដោយអ្នកថែទាំសុខភាព ដែលទទួលបានការបណ្តុះបណ្តាល និងត្រូវផ្តល់ឱ្យនៅកម្រិតសហគមន៍តាមការចាំបាច់ តាមលក្ខណៈដែលបង្ហាញនូវការគោរព និងលើកកំពស់ភាពថ្លៃថ្នូរ គ្មានការបង្ខិតបង្ខំ និងការមាក់ងាយដល់អ្នកជំងឺ និងមិនគិតពី អាយុ កំណើត សម្បុរ វប្បធម៌ សញ្ជាតិ ពិការភាព ជនជាតិដើមភាគតិច ស្ថានភាពហិរញ្ញវត្ថុ អត្តសញ្ញាណយេនឌ័រ ភាសា ក្របខណ្ឌច្បាប់ ទំនោរនយោបាយ ឬមតិផ្សេងទៀត ឬស្ថានភាពនៃជំងឺ ដើមកំណើត ជាតិសាសន៍ ឬសង្គម ពូជសាសន៍ សាសនា ភេទ ទំនោរផ្លូវភេទ

ឬក្នុងស្ថានភាពណាមួយផ្សេងទៀត ដោយរាប់បញ្ចូលទាំងអ្នកដែលត្រូវបានឃុំខ្លួនដោយរដ្ឋ ឬអ្នកដែលត្រូវបានគេដកហូតសេរីភាព ដោយយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមប្រជាជនគន្លឹះនៃជំងឺរបេងទាំងអស់។

## មាត្រា ៥. **សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងទង្វើអមនុស្សធម៌ ឬមាក់ងាយផ្សេងៗ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ពីជំងឺរបេងមានសិទ្ធិរួចផុតពីការធ្វើទារុណកម្ម  និងទង្វើអមនុស្សធម៌ ឬបន្ថោកបន្ទាបផ្សេងៗ។

នេះរួមបញ្ចូលទាំងសិទ្ធិទទួលបានការថែទាំសុខភាពសម្រាប់ជំងឺរបេងដោយគ្មានការរើសអើង និងជាបន្ទុករបស់រដ្ឋ សម្រាប់អ្នកដែលត្រូវបានឃុំខ្លួនដោយរដ្ឋ ឬសេរីភាពរបស់ពួកគេត្រូវបានដកហូត។ នេះក៏រួមបញ្ចូលផងដែរ នូវសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងលក្ខខណ្ឌនៃការនៅដាច់ដោយឡែក ដែលមានអនាម័យ ការនៅឆ្ងាយពីមនុស្សកកកុញជាមួយនឹងខ្យល់ចេញចូលគ្រប់គ្រាន់ និងការទទួលបានអាហារមានជីវជាតិគ្រប់គ្រាន់។ សិទ្ធិនេះ ក៏អនុវត្តទៅលើការព្យាបាលអ្នកជំងឺរបេង ដោយគ្រូពេទ្យថែទាំសុខភាពនៅតាមមណ្ឌលសុខភាពសាធារណៈ ក្នុងកម្រិតដែលពួកគេស្ថិតក្នុងលក្ខណៈនៃការធ្វើទារុណកម្ម ឬការព្យាបាទ ដោយទង្វើអមនុស្សធម៌នានាផងដែរ។

## មាត្រា ៦. **សិទ្ធិទទួលបានសមភាព និងសេរីភាពពីការរើសអើង**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង គឺទទួលបានសិទ្ធិ និងការការពារដោយច្បាប់ដោយគ្មានការរើសអើង និងមានសេរីភាពនូវគ្រប់ទម្រង់នៃការរើសអើងដូចជាអាយុ កំណើត សម្បុរ វប្បធម៌ សញ្ជាតិ ពិការភាព ជនជាតិ កម្រិតសេដ្ឋកិច្ច ក្របខណ្ឌច្បាប់ អត្តសញ្ញាណ យេនឌ័រ ភាសា ស្ថានភាពនយោបាយ ឬមតិផ្សេងទៀត វត្តមានជំងឺផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ពូជសាសន៍ សាសនា ភេទ ទំនោរផ្លូវភេទ ឬក្នុងស្ថានភាពណាមួយផ្សេងទៀតឡើយ។

នេះរួមបញ្ចូលទាំងសិទ្ធិ ដែលអ្នករងផលប៉ះពាល់ដោយសារជំងឺរបេង អាចរួចផុតពីការរើសអើងគ្រប់រូបភាពនៅគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ ដែលរួមបញ្ចូលនូវ ការមិនកំណត់ការទទួលបាននូវសន្តិ
សុខសង្គម និងសិទ្ធិជាសាធារណៈ ការសម្រាលកូន និងភាពជាម្តាយ ការអប់រំ ការងារ ការថែទាំសុខភាព លំនៅដ្ឋាន និងអាពាហ៍ពិពាហ៍។

## មាត្រា ៧. **សិទ្ធិទទួលបានសេរីភាព និងសន្តិសុខបុគ្គល**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ពីជំងឺរបេងមានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខបុគ្គល។ គ្មានអ្នកណាម្នាក់ដែលមានជំងឺរបេងបាត់បង់សេរីភាពរបស់ពួកគេឡើយ លើកលែងតែមានមូលហេតុណាមួយដែលស្របតាមនីតិវិធីដែលចែងឡើងដោយច្បាប់។ ហើយមនុស្សគ្រប់រូប ដែលរងផលប៉ះពាល់ដោយជំងឺរបេងដែលត្រូវបានដកហូតពីការទទួលបានសេរីភាពទាំងនោះ នៅតែទទួលបានការគោរពចំពោះ អ្វីដែលពួកគេមាន។

ការបង្ខិតបង្ខំដោយគ្មានការស្ម័គ្រចិត្ត ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការដាក់ដោយឡែកនៃអ្នកមានជំងឺរបេង គឺជាការដកហូតសិទ្ធិសេរីភាព និងការរំលោភលើសន្តិសុខបុគ្គលរបស់គេ។ ដូច្នេះការសម្រាកនៅមន្ទីរពេទ្យ ឬការដាក់ដាច់ដោយឡែក គឺអាចអនុញ្ញាតបានលុះត្រាតែជាដំណោះស្រាយចុងក្រោយដែលត្រូវបានកំណត់ក្នុងកាលៈទេសៈណាមួយ ហើយក្នុងរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន ស្របតាមជំពូក ១៥ នៃគោលការណ៍ណែនាំស្តីពីសីលធម៌ របស់អង្គការសុខភាពពិភពលោកសម្រាប់ការអនុវត្តយុទ្ធសាស្ត្របញ្ចប់ជំងឺរបេង ដោយផ្អែកលើភស្តុតាងវេជ្ជសាស្ត្រ នៅពេលដែលមនុស្សម្នាក់ៗ៖

- ត្រូវបានគេដឹងថាជាអ្នកបង្ករោគ បដិសេធមិនទទួលយកការព្យា បាលដែលមានប្រសិទ្ធភាព និងវិធានការសមស្រប ដើម្បីធានាបាននូវការប្រកាន់ភ្ជាប់នូវវិធានការ និងការបង្ហាញថាមិនជោគជ័យ
- ត្រូវបានគេដឹងថាជាអ្នកបង្ករោគ បានយល់ព្រមទទួលការព្យាបាលនៅផ្ទះ ប៉ុន្តែខ្វះសមត្ថភាពក្នុ ងការគ្រប់គ្រងការឆ្លងមេរោគរបេងនៅផ្ទះ និងបដិសេធការមើលថែទាំអ្នកជំងឺ
- ងាយនឹងឆ្លងខ្លាំង (ផ្អែកលើភស្តុតាងនៃមន្ទីរពិសោធន៍) ប៉ុន្តែបដិសេធមិនទទួលការព្យាបាលលើ ស្ថានភាពឆ្លងរបស់គាត់ ក្នុងអំឡុងពេលដែលការខិតខំប្រឹងប្រែងទាំងអស់បង្កើតឡើង ដើម្បី បង្កើតគម្រោងព្យាបាលសម្រាប់ពួកគេ។

លើសពីនេះទៅទៀត យោងតាមគោលការណ៍សីលធម៌ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ ស្តីពីការកំណត់ និងការដកហូតបទប្បញ្ញត្តិក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ការដកហូតសិទ្ធិសេរីភាពដែលពាក់ព័ន្ធនឹងការឃុំខ្លួន ការសម្រាកព្យាបាលនៅមន្ទីរពេទ្យឬការដាក់ឱ្យនៅដោយឡែកនៃអ្នកជំងឺរបេងគឺបានរាប់ជាសុចរិតភាពប្រសិនបើ៖

១. អនុលោមតាមច្បាប់ជាតិជាធរមាន នៅក្នុងពេលវេលានៃការដកហូត
២. ផ្អែកលើគោលបំណងស្របច្បាប់ ក្នុងការឆ្លើយតបទៅនឹងការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់សុខភាព ប្រជាជន ឬសមាជិកដទៃណាម្នាក់

៣. ទាមទារយ៉ាងម៉ឺងម៉ាត់ តាមតម្រូវការរបស់ស្ថានភាព
៤. មធ្យោបាយរឹតត្បិតតិចបំផុតដើម្បីសម្រេចបានគោលបំណង និង
៥. ការមិនបំពាន រំលោភបំពាន ឬរើសអើង

ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការដាក់ដោយឡែកនៃអ្នកដែលមានជំងឺរបេង អាចធ្វើទៅបានលុះត្រាតែកាលៈទេសៈខាងលើត្រូវបានអនុវត្តធ្វើឡើងតាមវិធានការវេជ្ជសាស្ត្រ ដោយមានការត្រួតពិនិត្យការឆ្លងរោគ ដែលមានប្រសិទ្ធភាព និងក្នុងរយៈពេលខ្លីបំផុត ហើយជននោះត្រូវបានគេផ្តល់ឱ្យនូវការថែទាំសុខភាពដោយការស្ម័គ្រចិត្ត ហើយសិទ្ធិនិងសេរីភាពរបស់ពួកគេត្រូវបានការពារ។ យន្តការនីតិវិធី និងដំណោះស្រាយត្រូវតែមាន និងអាចដំណើរការបាន ហើយរដ្ឋត្រូវបំពេញយ៉ាងហោចណាស់ នូវតម្រូវការមូលដ្ឋានរបស់មនុស្ស ដូចជាស្បៀងអាហារ និងទឹកបរិភោគគ្រប់គ្រាន់ ក៏ដូចជាតម្រូវការបន្ថែមទៀតដែលត្រូវការដើម្បីធានាការរឹតត្បិតសិទ្ធិរបស់ពួកគេ គឺសម្រាប់បម្រើគោលបំណងច្បាស់លាស់។

## មាត្រា ៨. **សេរីភាពក្នុងការធ្វើដំណើរ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង តាមផ្លូវច្បាប់ក្នុងដែនដីដែលគ្រប់គ្រងដោយរដ្ឋមានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរនិងសេរីភាពក្នុងការជ្រើសរើសទីលំនៅរបស់ពួកគេ។

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយជំងឺរបេងមានសេរីភាពក្នុងការចាកចេញពីប្រទេសណាមួយ ក៏ដូចជាប្រទេសដែលគេរស់នៅផងដែរ។

សិទ្ធិដែលបានរៀបរាប់ខាងលើនេះ គឺមិនអាស្រ័យលើការរឹតបន្តឹងណាមួយឡើយ លើកលែងតែច្បាប់ណាមួយដែលបានអនុម័តដោយរដ្ឋ ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សីលធម៌ ឬ សិទ្ធិនិងសេរីភាពរបស់អ្នកផ្សេងទៀតហើយក៏ស្របជាមួយនឹងសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិទទួលបានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន នៅក្នុងសេចក្តីប្រកាស ក្នុងមាត្រាទី៧។

នេះមានន័យថា ជំងឺរបេងមិនអាចប្រើជាហេតុផលសម្រាប់ការបដិសេធការចេញចូលទឹកដីដែលគ្រប់គ្រងដោយរដ្ឋ ហើយក៏មិនមែនជាហេតុផលសម្រាប់ការនិរទេសឬដកចេញពីទឹកដីនៃរដ្ឋដែរ។នេះក៏មានន័យថាជំងឺរបេងក៏មិនអាចប្រើជាមូលដ្ឋានក្នុងការរឹតត្បិត ឬការធ្វើដំណើរក្នុងប្រទេសរបស់អ្នកជំងឺរបេងដែរ លើកលែងតែពួកគេស្ថិតនៅក្នុងលក្ខខណ្ឌ កាលៈទេសៈណាមួយ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ មាត្រាទី៧ ដែលស្របនឹងអ្វីដែលមាននៅក្នុងជំពូកទី១៥ នៃគោលការណ៍ណែនាំសីលធម៌របស់អង្គការសុខភាពពិភពលោក សម្រាប់ការអនុវត្តយុទ្ធសាស្ត្របញ្ចប់ជំងឺរបេង។

## មាត្រា ៩. **សិទ្ធិទទួលបាននូវឯកជនភាព និងជីវិតគ្រួសារ**

មនុស្សគ្រប់រូប ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិ មិនត្រូវបានគេរំលោភបំពានច្បាប់លើការទទួលបាននូវឯកជនភាពរបស់ពួកគេ គ្រួសាររបស់ពួកគេ លំនៅដ្ឋានរបស់គេ ឬការទំនាក់ទំនងរបស់ពួកគេទេ ហើយក៏មិនមានការវាយប្រហារដោយខុសច្បាប់លើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេដែរ។

មនុស្សគ្រប់រូប ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបានការការពារដោយច្បាប់ ប្រឆាំងនឹងការវាយប្រហារផ្សេងៗ។ នេះរួមបញ្ចូលទាំងការទទួលបានការរក្សាការសម្ងាត់នៃស្ថានភាពសុខភាព ព័ត៌មានសុខភាពផ្ទាល់ខ្លួន និងទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ វាក៏រួមបញ្ចូលទាំងសិទ្ធិទទួលបានអាពាហ៍ពិពាហ៍ គ្រួសារ និងការថែទាំកូនរបស់គេផងដែរ។

## មាត្រា ១០. **សិទ្ធិទទួលបានការរក្សាការសម្ងាត់**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបានការរក្សាការសម្ងាត់នៃស្ថានភាព និងទិន្នន័យសុខភាពរបស់ពួកគេ។

នេះមានន័យថា ការបង្ហាញ ការចែករំលែកនូវព័ត៌មាន ឬទិន្នន័យផ្សេងៗរបស់អ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ដូចដែលមានចែងក្នុងច្បាប់ការងារគឺអាចអនុញ្ញាតិឱ្យធ្វើបានលុះត្រាតែមានការអនុញ្ញាតពីអ្នកជំងឺ និងនៅក្នុងគោលបំណងថែទាំសុខភាពរបស់ពួកគេ ឬសម្រាប់ការការពារសុខភាពសាធារណៈ។

សម្រាប់គោលបំណងការពារសុខភាពសាធារណៈ រួមបញ្ចូលទាំងការស្រាវជ្រាវសុខភាពសាធារណៈឬកម្មវិធីផ្តល់សេវាសុខភាព ព័ត៌មានទាំងនេះអាចចែករំលែក ឬផ្ទេរព័ត៌មានដោយមិនមានការព្រមព្រៀងពីអ្នកជំងឺប្រសិនបើ ការធ្វើឡើងដោយមិនមានការបញ្ចេញអត្តសញ្ញាណរបស់អ្នកជំងឺ។ សិទ្ធិក្នុងការរក្សាការសម្ងាត់ក៏ត្រូវគោរព និងរាប់បញ្ចូលក្នុងការរៀបចំ និងអនុវត្តនៃការតាមដានទំនាក់ទំនង និងអន្តរាគមន៍សុខភាពសាធារណៈដទៃទៀតដែលពាក់ព័ន្ធផងដែរ។ នេះរួមបញ្ចូលការទទួលបានការប្រឹក្សាយោបល់សម្រាប់អ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ការចូលរួមក្នុងការធ្វើសេចក្តីសម្រេច អំពីរបៀប និងពេលវេលាដែលត្រូវប្រាប់អ្នកដែលមានទំនាក់ទំនងជាមួយនូវស្ថានភាពដែលគេអាចឆ្លងជំងឺ និងធានាបាននូវការជួបជាមួយអ្នកដែលផ្តល់សេវាថែទាំសុខភាពដែលទទួលបានការបណ្តុះបណ្តាល និងអ្នកធ្វើការផ្នែកសង្គម ដើម្បីផ្តល់ការគាំទ្រ និងឆ្លើយសំណួរដែលអាចកើតមាន ក្នុងពេលណាមួយ។

## មាត្រា ១១. **សិទ្ធិទទួលបានព័ត៌មាន**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិស្វែងរក ទទួលបាន និងចែកចាយព័ត៌មាន។

នេះមានន័យថាព័ត៌មានអំពីការឆ្លងជំងឺរបេង និងជំងឺផ្សេងៗដែលរួមបញ្ចូលទាំងរោគសញ្ញានៃជំងឺ ការស្រាវជ្រាវវេជ្ជសាស្ត្រនៃជំងឺរបេង ការអភិវឌ្ឍបច្ចេកវិទ្យាសុខាភិបាល សេវាបង្ការ សេវាធ្វើតេស្ត និងសេវាព្យាបាល រួមទាំងព្រឹត្តិការណ៍មិនល្អដែលអាចកើតមានក្នុងកំឡុងពេលព្យាបាល គប្បីត្រូវទទួលបាន រកបាន និងទទួលយកបាន ដែលមានគុណភាពល្អ អាយុ យែនឌ័រ ការយល់ដឹងអំពីវប្បធម៌ និងបង្ហាញក្នុងលក្ខណៈមិនស្ថិតក្នុងទម្រង់បច្ចេកទេស មានលក្ខណៈទូទៅ ក្នុងភាសាមួយ ដែលអាចយល់បានពីអ្នកដែលទទួលបានព័ត៌មានទាំងនោះ។

វាក៏មានន័យថា មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយជំងឺរបេងនៅកម្រិតអប្បបរមា ក៏មានសិទ្ធិក្នុងការៈ

- ស្នើសុំ និងទទួលបានច្បាប់ចម្លងជាផ្លូវការនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់ពួកគេ
- ទទួលបានការពន្យល់ទាន់ពេលវេលា ត្រឹមត្រូវ និងអាចយល់បានអំពីស្ថានភាពសុខភាពរបស់ពួ កគេ និងការធ្វើរោគវិនិច្ឆ័យរកជំងឺរបេង ឬការបង្ករោគ ជាពិសេសសម្រាប់ប្រជាជនគន្លឹះ និងងាយ រងគ្រោះដោយសារជំងឺរបេង។
- ទទួលបានការប្រឹក្សាយោបល់ដោយស្ម័គ្រចិត្តនៅពេលណាមួយ ចាប់ពីការធ្វើរោគវិនិច្ឆ័យរហូតដល់ ការព្យាបាលត្រូវបានបញ្ចប់ និង
- ទទួលបានការពន្យល់អំពីអត្ថប្រយោជន៍ ហានិភ័យ និងការចំណាយផ្នែកហិរញ្ញវត្ថុនៃការទទួលការ ព្យាបាលរបស់ពួកគេ ដូចជាវិធីព្យាបាលបង្ការ ក៏ដូចជាជម្រើសនៃការព្យាបាល ជាមួយនឹងព័ត៌មាន ជាក់លាក់អំពីថ្នាំ ដូចជាឈ្មោះថ្នាំ កម្រិតនៃការប្រើប្រាស់ ផល ប៉ះពាល់នៃថ្នាំ និងវិធីការពារ ឬកាត់ បន្ថយនូវការកើតឡើងដែលអាចមាន ក៏ដូចជាផលប៉ះពាល់ដែលអាចកើតមានពីអន្តរកម្មជាមួ យថ្នាំដទៃទៀតដូចជាថ្នាំប្រឆាំងនឹងមេរោគអេដស៍ ក្នុងពេលដែលមានជំងឺទាំងពីរ។

## មាត្រា ១២. **សិទ្ធិទទួលបាននូវការជូនដំណឹងនិងយល់ព្រមជាមុន**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបាននូវការជូនដំណឹងនិងយល់ព្រមជាមុន។

នេះមានន័យថា ការគោរពស្វ័យភាពរបស់បុគ្គល ការប្តេជ្ញាចិត្តរបស់បុគ្គល និងសេចក្តីថ្លៃថ្នូរ តាម រយៈការផ្តល់សេវាសុខភាពដោយស្ម័គ្រចិត្ត។

នេះរួមបញ្ចូលនូវសិទ្ធិនៃការជូនដំណឹងនិងយល់ព្រមជាមុនដែលធ្វើឡើងដោយផ្ទាល់មាត់ ឬដោយសរសេរ គឺអាស្រ័យលើស្ថានភាព ទៅលើគ្រប់ទម្រង់នៃការធ្វើតេស្ត ការផ្តល់កា រព្យាបាល និងការស្រាវជ្រាវវេជ្ជសាស្ត្រដែលទាក់ទងនឹងជំងឺរបេងដោយមានព័ត៌មានអំពីអាយុយេនឌ័រសមស្របគោរពស្ថានភាពវប្បធម៌ប្រពៃណី  ដោយមិនប្រើពាក្យបច្ចេកទេស មានទម្រង់ទូលំទូលាយក្នុងភាសាដែលប្រើ ដែលអាចយល់បានពីអ្នកដែលទទួលបានព័ត៌មាន។ ចំពោះកុមារដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ដែលខ្វះសមត្ថភាពក្នុងការផ្តល់ការយល់ព្រម នោះរាល់ការសម្រេចចិត្ត គឺធ្វើដោយឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ ទាក់ទងនឹងការធ្វើតេស្ត ការព្យាបាល ឬការស្រាវជ្រាវវេជ្ជសាស្ត្រដែលទាក់ទងនឹងជំងឺរបេងដោយឈរលើគុណប្រយោជន៍សំខាន់បំផុតចំពោះកុមារ ផ្អែកលើភស្តុតាងវេជ្ជសាស្ត្រត្រឹមត្រូវ។

សិទ្ធិទទួលបាននូវការជូនដំណឹងនិងយល់ព្រមជាមុន រួមមានសិទ្ធិក្នុងការបដិសេធការថែទាំសុខភាពសម្រាប់ជំងឺរបេង ស្របតាមជំពូកទី១៥ នៃគោលការណ៍ណែនាំស្តីពីក្រមសីលធម៌ របស់អង្គការសុខភាពពិភពលោក សម្រាប់ការអនុវត្តយុទ្ធសាស្ត្របញ្ចប់ជំងឺរបេង។ គោលការណ៍ណែនាំពីសីលធម៌នេះ បង្កើតឡើងដោយបញ្ជាក់ថា វាមិនមែនជារឿងត្រឹមត្រូវទេ ក្នុងការបង្ខំមនុស្សឱ្យព្យាលបាលអំពីជំងឺរបេង ពីព្រោះក្នុងចំណោមរឿងផ្សេងៗជាច្រើនទៀត គឺស្មើនឹងការជ្រៀតជ្រែកនូវសេចក្តីថ្លៃថ្នូរខាងរូបរាងកាយ និងអាចបណ្តាលឱ្យបុគ្គលិកផ្តល់សេវាថែទាំសុខភាពមានគ្រោះថ្នាក់។

## មាត្រា ១៣. **សិទ្ធិទទួលបានការអប់រំ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិទទួលបានការអប់រំ។នេះរួមបញ្ចូលទាំងសិទ្ធិទទួលបានការអប់រំកម្រិតបឋមសិក្សាដោយសេរី និងចាំបាច់ និងសិទ្ធិទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សារួមទាំងការអប់រំបច្ចេកទេសវិជ្ជាជីវៈដោយផ្អែកលើការមិនរើសអើង រួមទាំងជនពិការដោយត្រចៀក ចក្ខុចុះខ្សោយ ឬស្មារតីមិនល្អ។ កុមារដែលមានជំងឺរបេងមានសិទ្ធិទទួលបានកន្លែងស្នាក់នៅពេលពួកគេឆ្លងជំងឺ និងពេលពួកគេកំពុងទទួលការព្យាបាល ដោយត្រូវបានលើកលែងពីវិធានការផ្សេងៗដើម្បីអនុញ្ញាតឱ្យពួកគេបន្តការសិក្សាដោយគ្មានការរំខានដូចជា ការចូលរួមក្នុងថ្នាក់រៀនពីចម្ងាយ និងការសិក្សាតាមអ៊ីនធឺណែត។ ក្នុងកាលៈទេសៈដ៏កម្រដែលកុមាររងគ្រោះដោយសារជំងឺរបេងតម្រូវឱ្យមានការសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងរយៈពេលយូរ ពួកគេមានសិទ្ធិទទួលបានការរៀនសូត្រពីចម្ងាយ ក្នុងកំឡុងពេលព្យាបាលផងដែរ។

## មាត្រា ១៤. **សិទ្ធិធ្វើការងារ ឬទទួលបានការងារ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយជំងឺរបេងមានសិទ្ធិធ្វើការ ឬទទួលបានការងារ ហើយគ្មានអ្នកជំងឺរបេងណាម្នាក់

ត្រូវបានជាប់ជាទាសករឬត្រូវទទួលរងនូវការបង្ខិតបង្ខំឬកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។

## មាត្រា ១៥. **សិទ្ធិទទួលបានអាហារសមរម្យ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ និងរួចផុតពីភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ។

នេះរួមបញ្ចូលទាំងសិទ្ធិ មានរូបរាងកាយ និងទទួលបាននូវសេដ្ឋកិច្ចគ្រប់ពេលវេលា ទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ ប្រកបដោយជីវជាតិ និងមានសុវត្ថិភាពគ្រប់ពេលវេលា ដោយសំខាន់បំផុតគឺក្នុងអំឡុងពេលនៃការថែទាំសុខភាពពាក់ព័ន្ធនឹងជំងឺរបេង រួមទាំងប្រជាជនដែលត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេផងដែរ។ ក្នុងនេះក៏រួមបញ្ចូលការព្យាបាលផ្នែកអាហារូបត្ថម្ភ ដែលជាលក្ខខណ្ឌតំរូវក្នុងការព្យាបាលជំងឺរបេង។

## មាត្រា ១៦. **សិទ្ធិទទួលបានលំនៅដ្ឋាន**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបានលំនៅដ្ឋានរស់នៅ សមរម្យ។

នេះរួមបញ្ចូលទាំងសិទ្ធិទទួលបានលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងអាចរស់នៅបានក្នុងទីតាំងដែលអាចទទួលយកបាន ដោយមានសិទ្ធិកាន់កាប់ដែលធានាការការពារស្របច្បាប់ ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ការយាយី និងការគំរាមកំហែងនានា។ នេះក៏រួមបញ្ចូលផងដែរនូវភាពអាចរកបាននៃសេវាកម្ម សម្ភារបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផ្នែកសំខាន់ផ្សេងៗទៀត រួមមានអនាម័យ និងមានខ្យល់ចេញចូលគ្រប់គ្រាន់ មានកម្តៅ ពន្លឺ និងការបញ្ចេញនូវកាកសំណល់ផងដែរ។

## មាត្រា ១៧. **សិទ្ធិទទួលបានទឹកស្អាត និងអនាម័យ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ពីជំងឺរបេងមានសិទ្ធិទទួលបានទឹកស្អាតនិងអនាម័យ។

នេះរួមបញ្ចូលទាំងសិទ្ធិទទួលបានទឹកបរិភោគស្អាត និងសេវាកម្មអនាម័យគ្រប់គ្រាន់ដោយគ្មានការរើសអើង ជាពិសេសនៅតាមជនបទ ជនជាតិដើមភាគតិចនិងទីក្រុងដែលមានការអភិវឌ្ឍនៅមានកម្រិតរួមទាំងការតាំងទីលំនៅក្រៅផ្លូវការ និងប្រជាជនគ្មានផ្ទះសម្បែង ដោយផ្តោតជាពិសេសលើតម្រូវការរបស់ស្ត្រីនិងកុមារ។

## មាត្រា ១៨. **សិទ្ធិទទួលបានសន្តិសុខសង្គម**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបាននូវសន្តិសុខសង្គម និងការធានារ៉ាប់រងសង្គម រួមទាំងក្នុងករណីដែលគ្មានការងារធ្វើ ក្លាយជាជនពិការ ចាស់ជរា ឬស្ថានភាពផ្សេងទៀត នៃការបាត់បង់មធ្យោបាយនៃការចិញ្ចឹមជីវិតដោយហេតុផលហួសពីការគ្រប់គ្រងរបស់ពួកគេ។

នេះមានន័យថាមនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិទទួលបាននូវសន្តិសុខសង្គមគ្រប់ប្រភេទដោយគ្មានការរើសអើង ទោះបីជាពួកគេមិនបានទទួលការថែទាំសុខភាពពាក់ព័ន្ធនឹងជំងឺរបេង ឬមិនបានព្យាបាលជំងឺរបេងឱ្យបានជាប់លាប់ក៏ដោយ។

នេះរាប់បញ្ចូលទាំងសិទ្ធិក្នុងការទទួលបាន និងរក្សាអត្ថប្រយោជន៍ផ្សេងៗ មិនថាជាសាច់ប្រាក់ ឬសម្ភាររូបវ័ន្ត ដើម្បីទទួលបានកិច្ចគាំពារក្នុងចំណោមរបស់ផ្សេងទៀត៖ កង្វះប្រាក់ចំណូលពីការងារដែលបណ្តាលមកពីជំងឺ ពិការភាព មាតុភាព របួសការងារ ភាពអត់ការងារធ្វើ ចាស់ជរា ឬ មរណភាពនៃសមាជិកគ្រួសារនីមួយៗ មិនមានលទ្ធភាពទទួលបានការថែទាំសុខភាព ឬការផ្គត់ផ្គង់គ្រួសារមិនគ្រប់គ្រាន់សម្រាប់កុមារ និងមនុស្សធំពេញវ័យក្នុងបន្ទុក ជាពិសេសមនុស្សគ្រប់រូបដែលឆ្លងជំងឺរបេង ឬមានជំងឺដែលជាលទ្ធផលនៃការងាររបស់ពួកគេមានសិទ្ធិទទួលបានសំណងសម្រាប់ថ្លៃព្យាបាល និងការចំណាយផ្សេងទៀតដែលទាក់ទងដល់ការប៉ះពាល់ការងាររបស់ពួកគេ។

## មាត្រា ១៩. **សិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។

សិទ្ធិទាំងនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ ស្វែងរក ទទួលបាន និងការចែកចាយព័ត៌មាន និងគំនិតផ្សេងៗ រួមទាំងអំពីជំងឺរបេង និងបទពិសោធន៍របស់បុគ្គលដែលរស់នៅជាមួយជំងឺរបេងតាមរយៈមជ្ឈដ្ឋានណាមួយ ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយគ្មានការជ្រៀតជ្រែក ឬការដាក់ទណ្ឌកម្មពីអាជ្ញាធរសាធារណៈ។

## មាត្រា ២០. **សិទ្ធិសេរីភាពក្នុងការជួបជុំ និងសមាគម**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិសេរីភាពក្នុងការជួបជុំដោយសន្តិវិធី និងចូលរួមសមាគម ឬជាមួយក្រុមដទៃទៀត។

នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការបង្កើត ការចូលរួម និងចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍ និងសម្រាប់ប្រជាជនដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ដែលមានគោលបំណងលើកកម្ពស់ និងការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់ក្រុមខ្លួនឯងរួមទាំងនៅក្នុងកន្លែងឃុំឃាំង។ នេះក៏រួមបញ្ចូលទាំងសិទ្ធិក្នុងការរៀបចំ ការប្រមូលផ្តុំ និងការតវ៉ាដោយសន្តិវិធីនៅតាមទីសាធារណៈជុំវិញបញ្ហាដែលទាក់ទងនឹងជំងឺរបេង។

ការអនុវត្តសិទ្ធិទាំងនេះ តម្រូវឱ្យមានបរិយាកាសស្របច្បាប់ និងគោលនយោបាយអំណោយផលដែលអនុញ្ញាត សម្របសម្រួល បង្កើត និងប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍ និងសម្រាប់ប្រជាជនដែលរងផលប៉ះពាល់ដោយសារជំងឺរបេង។ គ្មានការរឹតត្បិតណាមួយ អាចត្រូវបានដាក់លើការអនុវត្តសិទ្ធិទាំងនេះទេ ក្រៅពីសិទ្ធិដែលបានកំណត់ដោយច្បាប់ និងចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការពារភាពមិនចុះសម្រុង និងបទឧក្រិដ្ឋ ការការពារសុខភាព និងសីលធម៌ ឬសម្រាប់ការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។ នេះមិនរារាំងការណែនាំអំពីការដាក់កម្រិតស្របច្បាប់ លើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬអាជ្ញាធរអនុវត្តច្បាប់ឡើយ។

## មាត្រា ២១. **សិទ្ធិក្នុងការចូលរួមជាសាធារណៈ**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងមានសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈស្ថាប័នរបស់ពួកគេ និងជ្រើសរើសតំណាងដោយសេរី។

នេះរួមបញ្ចូលទាំងសិទ្ធិចូលរួមប្រកបដោយអត្ថន័យនៅក្នុងគ្រប់ដំណើរការ និងយន្តការសម្រាប់ការអភិវឌ្ឍ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ គោលការណ៍ណែនាំ ថវិកា និងកម្មវិធីពាក់ព័ន្ធនឹងជំងឺរបេង ការថែទាំសុខភាពសម្រាប់ជំងឺរបេង និងការស្រាវជ្រាវវេជ្ជសាស្ត្រសម្រាប់ជំងឺរបេង នៅគ្រប់កម្រិតអភិបាលកិច្ច ដោយមានការគាំទ្រ កន្លែងស្នាក់នៅសមរម្យផ្តល់ដោយរដ្ឋ អង្គការអន្តរជាតិ ក្រុមជនជាតិដើមភាគតិច និងអង្គការសង្គម ស៊ីវិលនៅពេលចាំបាច់ ដើម្បីធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងប្រសិទ្ធិភាព។

## មាត្រា ២២. **សិទ្ធិទទួលបានភាពយុត្តិធម៌ និងដំណើរការផ្សេងទៀត**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ដែលត្រូវបានចោទប្រកាន់ពីបទល្មើស រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងដោយគ្មានការពន្យារពេលដោយតុលាកា

រមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលត្រូវបានបង្កើតឡើងដោយច្បាប់និងមានមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា នៅពេលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។

នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងតាមរបៀបដែលបានកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិ រាប់បញ្ចូលទាំងអាជ្ញាធរសុខភាពសាធារណៈ និងដើម្បីឱ្យមានសវនាការយុត្តិធម៌ ត្រឹមត្រូវ នៃពាក្យបណ្តឹងទាំងនេះ។ នេះក៏រួមបញ្ចូលផងដែរ ទាំងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទៅអាជ្ញាធរជាន់ខ្ពស់ ប្រសិនបើពួកគេមិនពេញចិត្តនឹងលទ្ធផលនៃការកាត់ក្តី ហើយទទួលបានការសម្រេចចិត្ត និងហេតុផលនៃបញ្ហារបស់ពួកគេជាលាយលក្ខណ៍អក្សរជាភាសាដែលពួកគេយល់។

## មាត្រា ២៣. **សិទ្ធិទទួលបានអត្ថប្រយោជន៍នៃវឌ្ឍនភាពវិទ្យាសាស្ត្រ (សិទ្ធិវិទ្យាសាស្ត្រ)**

មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេង មានសិទ្ធិទទួលបានអត្ថប្រយោជន៍ នៃវឌ្ឍនភាពវិទ្យាសាស្ត្រ និងការប្រើប្រាស់នានា។

នេះមានន័យថា មនុស្សគ្រប់រូបដែលរងផលប៉ះពាល់ដោយសារជំងឺរបេងត្រូវតែមានលទ្ធភាពទទួលបានការជឿនលឿនផ្នែកវិទ្យាសាស្ត្រដោយគ្មានការរើសអើង ការគោរព និងការពារចនធានធម្មជាតិរបស់ជនជាតិដើមភាគតិច បុគ្គល និងសមូហភាពកម្មសិទ្ធិបញ្ញា មិនថាការជឿនលឿនទាំងនេះជាវត្ថុអរូបីយដូចជាចំណេះដឹង និងព័ត៌មាន ឬលទ្ធផលជាក់ស្តែង ដូចជាបច្ចេកវិទ្យាថ្មីសម្រាប់ការងារបង្ការ ការធ្វើរោគវិនិច្ឆ័យ ឬការព្យាបាលជំងឺរបេង។ នេះក៏រួមបញ្ចូលទាំងសិទ្ធិក្នុងការចូលរួម ក្នុងដំណើរការវិទ្យាសាស្ត្រពីការរៀបចំផែនការស្រាវជ្រាវ ចូលរួមក្នុងការសាកល្បងព្យាបាល។

សិទ្ធិវិទ្យាសាស្ត្រក៏ទាមទារឱ្យរដ្ឋទំនុកបម្រុង អភិវឌ្ឍ និងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្រ និងគុណប្រយោជន៍របស់វាផងដែរ។ នេះមានន័យថា រដ្ឋាភិបាលត្រូវតែ៖ វិនិយោគ និងរៀបចំគោលនយោបាយ ហើយគោលនយោបាយទាំងនោះអាចជួយដល់ការស្រាវជ្រាវ។ ការធ្វើឱ្យវិទ្យាសាស្ត្រ និងកម្មវិធីរបស់វាអាចប្រើបានយ៉ាងទូលំទូលាយ ក្នុងចំណោមកម្មវិធីផ្សេងទៀត ត្រូវផ្សព្វផ្សាយលទ្ធផល បង្កើតប្រព័ន្ធបទប្បញ្ញត្តិ ដើម្បីវាយតម្លៃអន្តរាគមន៍ថ្មីៗ និងផ្អែកលើកម្មវិធី និងគោលនយោបាយសុខភាពសាធារណៈជាភស្តុតាងវិទ្យាសាស្ត្រ និងធានាបាននូវវឌ្ឍនភាពវិទ្យាសាស្ត្រ ហើយគុណប្រយោជន៍របស់វាត្រូវបានថែរក្សាសំរាប់មនុស្សជំនាន់ក្រោយ។

## ជំពូក ៣. កាតព្វកិច្ច និងការខុសត្រូវ

### មាត្រា ២៤. កាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងថ្នាក់តំបន់

រដ្ឋមានកាតព្វកិច្ចស្របច្បាប់ដែលបង្កើតឡើងដោយច្បាប់សិទ្ធិមនុស្ស អន្តរជាតិ និងក្នុងតំបន់ ដើម្បីគោរពការពារ និងបំពេញសិទ្ធិមនុស្សរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយសារជំងឺរបេង រួមទាំងសិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះផងដែរ។

១. **កាតព្វកិច្ចក្នុងការគោរព៖** រដ្ឋត្រូវតែបញ្ឈប់ពីការជ្រៀតជ្រែកនៃកា រទទួលបានសិទ្ធិពីអ្នកដែលរង ផលប៉ះពាល់ដោយសារជំងឺរបេង។
២. **កាតព្វកិច្ចក្នុងកិច្ចការពារ៖** រដ្ឋត្រូវតែចាត់វិធានការនានា ដើម្បីរា រាំងភាគីទី៣ ដែលរួមបញ្ចូល ទាំងភាគីក្រៅ រដ្ឋាភិបាល ដូចជាអ្នកផ្តល់សេវាសុខភាពឯកជន ក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជន ឱសថស្ថាន និងកន្លែងធ្វើរោគវិនិច្ឆ័យ និងភាគីផ្សេងទៀត ចំពោះការជ្រៀតជ្រែក ក្នុ ងការទទួលបានសិទ្ធិរបស់អ្នកដែល រងផលប៉ះពាល់ដោយសារជំងឺរបេង។
៣. **កាតព្វកិច្ចក្នុងការបំពេញការងារ៖** រដ្ឋត្រូវតែអនុម័តនូវនីតិប្បញ្ញត្តិ កិច្ចការរដ្ឋបាល ការរៀបចំ ថវិកា ការផ្សព្វផ្សាយ និងវិធានការផ្សេងៗទៀត ជាអតិបរិមាចំពោះធនធានដែលមានសម្រាប់ ដើម្បីឆ្ពោះទៅរកការសម្រេចបានពេញលេញនូវសិទ្ធិរបស់អ្នកដែលរងផលប៉ះពាល់ដោ យសារជំងឺរបេង។

### មាត្រា ២៥. ការទទួលខុសត្រូវរបស់ភាគីក្រៅរដ្ឋាភិបាលក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងថ្នាក់តំបន់

ស្ថាប័នក្រៅរដ្ឋាភិបាលដែលរួមបញ្ចូលសហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដូចជាអ្នកផ្តល់សេវាថែទាំសុខភាពឯកជន ស្ថាប័នធានារ៉ាប់រងសុខភាពឯកជន ឱសថស្ថាន និងកន្លែងធ្វើរោគវិនិច្ឆ័យ និងស្ថាប័នដទៃទៀត មានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិ របស់អ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេង រួមទាំងសិទ្ធិ ដែលមានចែងនៅក្នុងច្បាប់នៅក្នុងសេចក្តីប្រកាសនេះផងដែរ។ ស្ថាប័នក្រៅរដ្ឋាភិបាលទាំងនេះ គួរតែជៀសវាងការរំលោភលើសិទ្ធិអ្នករងផលប៉ះពាល់ដោយសារជំងឺរបេង ហើយគួរតែដោះស្រាយនូវផលប៉ះពាល់អវិជ្ជមាននានាដែលប៉ះពាល់ដល់អ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង ដែលពួកគេបានចូលរួម។

បោះពុម្ពផ្សព្វផ្សាយ នៅខែឧសភា ឆ្នាំ២០១៩

ទំនាក់ទំនងទៅកាន់ TBpeople:

facebook.com/tbpeople, twitter @realTBpeople,
info@tbpeople.org.uk

ទំនាក់ទំនងទៅកាន់ Stop TB Partnership:

facebook.com/StopTBPartnership,
instagram.com/stoptb, twitter @StopTB,
www.stoptb.org, communications@stoptb.org

# សេចក្តីប្រកាសស្តីពី សិទ្ធិ
# អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង



ការសម្របសម្រួលបកប្រែភាសា នៃសេចក្តីប្រកាសស្តីពីសិទ្ធិរបស់ អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង ទៅជាភាសាខ្មែរ ដោយ អង្គការខាណា ជាមួយនឹងការគាំទ្រពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន និង Stop TB Partnership

សេចក្តីប្រកាសស្តីពីសិទ្ធិរបស់អ្នករងផលប៉ះពាល់ដោយសារជំងឺរបេង គឺមួយផ្នែកទទួលបានការគាំទ្រពីប្រជាពលរដ្ឋអាមេរិក តាមរយៈ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)

KHANA
រួមគ្នាដើម្បីសហគមន៍កាន់តែរឹងមាំ

TB PEOPLE

APCASO
Strengthening community systems.
Advancing human rights.

Stop TB Partnership

មជ្ឈមណ្ឌលជាតិកំចាត់រោគ របេង និង ហង់សិន
National Center for Tuberculosis and Leprosy Control (CENAT)